ចំណង់ និង មធ្យោបាយ

តើជនស្នេហាជាតិណាម្នាក់ គ្មានចំណង់នឹងធ្វើអ្វីមួយ ដើម្បីប្រយោជន៍ជាតិ តែចំណង់នោះ វារមែងហៅរកមធ្យោបាយដើម្បី ធ្វើឲបានសម្រេច។ បើចំណង់នោះ វាមានកំរិតខ្ពស់ វាក៏ត្រូវមាន មធ្យោបាយ ជាសមាមាត្រផងដែរ, ពុំនោះសោត វាគ្រាន់តែជាគំនិតហួសវិស័យប៉ុណ្ណោះ។ នៅក្នុងការតស៊ូ ដើម្បីប្រយោជន៍ជាតិ វាត្រូវអោយមាន សេចក្តីក្លាហាន និង ការគិតស្មាន ហើយ ការគិតស្មាននោះទៀត វារមែងមានគ្រោះថ្នាក់គ្រប់ជាន់ថ្នាក់។ ការទទួលយក នៃគ្រោះថ្នាក់ វាសំដែងបន្តបន្ទាប់ នូវការប្រុងប្រយ័ត្ន និង ភាពមោះមុត, វាក៏ជា ល្បែងនៃ លទ្ធិភាព និង ភវនីយភាព, ជោគល្អ ឬ អាក្រក់ បន្ត ក្នុងជំហានតូច ឬ ធំ ម្តងមួយជំហាន ដែលត្បាញ នូវដំណើរប្រទាក់ឆ្នាក់ ដែលទុកជាសិល្បៈ នៃការគ្រប់គ្រងការតស៊ូ ដើម្បីប្រយោជន៍ជាតិ។

កំហុស តន្ទើន គឺយល់ច្រឡំ នូវមូលហេតុមួយផ្នែក នៃការតស៊ូជាមួយនឹងគោលដៅទាំងអស់ នៃការតស៊ូ។ វប្បធម៌សន្ទនា ជាមូលហេតុមួយផ្នែក តែគោលដៅទាំងអស់ គឺប្តូររបបដឹកនាំផ្តាច់ការ, ដូច្នេះ មធ្យោបាយ ជាកូនសោ វាមិនមែនស្ថិតនៅលើដៃជនផ្តាច់ការ ដូចការយល់ឃើញនោះឡើយ, ផ្ទុយទៅវិញ វាស្ថិតនៅលើដៃប្រជាពលរដ្ឋ។ បើគ្មានប្រជាពលរដ្ឋ គឺមិនអាចធ្វើឲបានសម្រេច នូវគោលចំណង់ជាដាច់ខាត៕

ឧប សៅ សង្ហា　　　　គំនិត　　　　១៥ មិថុនា ២០១៩